# 24 한국 영화를 보면서 공부해요

## មើលភាពយន្តកូរ៉េបណ្ដើរ រៀនបណ្ដើរ

**학습 안내**
ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | និយាយអំពីវិធីសាស្ត្រក្នុងការរៀនសូត្រ, ការណែនាំអំពីវិធីសាស្ត្រក្នុងការចុះឈ្មោះ |
| □ វេយ្យាករណ៍ | -(으)면서, -기 쉽다/어렵다 |
| □ ពាក្យថ្មី | ការរៀនសូត្រ, ការអប់រំ |
| □ ព័ត៌មាន・វប្បធម៌ | កម្មវិធីអប់រំ(បណ្ដុះបណ្ដាល)សម្រាប់ពលករបរទេស |

## 대화 1 ការសន្ទនា ១

Track 76



ខាងក្រោមនេះគឺការសន្ទនារវាងស៊ូភីខានិងហៀអង។ ស៊ូភីខាកំពុងតែសួរហៀអងអំពីវិធីសាស្ត្រក្នុងការរៀនភាសាកូរ៉េ។ សូមស្ដាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

**수피카** 흐엉 씨, 주말에 시간이 있어요?
ហៀអង! តើនៅចុងសប្ដាហ៍នេះមានពេលទំនេរដែររឺទេ?

**흐 엉** 네, 그런데 왜요? ចា! មាន។ ប៉ុន្តែ មានរឿងអ្វីដែរ?

**수피카** 한국어가 너무 어려워서 그러는데 한국어 좀 가르쳐 주세요.
ភាសាកូរ៉េពិតជាពិបាកណាស់ អញ្ចឹងហើយ សូមជួយបង្រៀនខ្ញុំផង។

**흐 엉** 좋아요. បាន។

**수피카** 그런데 흐엉 씨는 한국어를 어떻게 공부해요? 학원에 다녀요?
ចុះហៀអងវិញ តើរៀនភាសាកូរ៉េបានដោយរបៀបណា? តើរៀននៅសាលាបង្រៀនភាសាកូរ៉េ មែនដែរឬទេ?

**흐 엉** 아니요, 저는 영화 보는 것을 좋아해서 한국 영화를 보면서 공부해요. 수피카 씨도 좋아하는 것을 하면서 공부해 보세요.
មិនមែនទេ, ខ្ញុំចូលចិត្តមើលភាពយន្តណាស់ ហេតុនេះហើយ មើលភាពយន្តកូរ៉េបណ្ដើរ រៀនបណ្ដើរ។ ស៊ូភីខាក៏សាកល្បងធ្វើអ្វីដែលខ្លួនចូលចិត្តបណ្ដើរ ហើយរៀនបណ្ដើរទៅមើល។

> **그런데** ប៉ុន្តែ
> ប្រើប្រាស់ទម្រង់នេះដើម្បីបង្វែរទិសដៅក្នុងការសន្ទនារបស់ដៃគូ។ សូមបញ្ជាក់ថាប្រយោគខាងក្រោយនេះនៅតែមានទំនាក់ទំនងជាមួយប្រយោគខាងមុខដដែលគ្រាន់តែបង្វែរទិសដៅនៃការសន្ទនាប៉ុណ្ណោះ។
> · 가: 오후에 시장 구경 갈까요?
> តើថ្ងៃរសៀលនេះ ទៅផ្សារជាមួយគ្នាដែរឬទេ?
> 나: 그런데 좀 늦게 가요. 먼저 할 일이 좀 있어서요.
> ទៅ, ក៏ប៉ុន្តែទៅរាងយឺតបន្តិចហើយ។ ពីព្រោះមានការងារត្រូវធ្វើបន្តិចបន្តួច។

> **-아서/어서 그러는데**
> ដោយសារតែ...... ហេតុនេះហើយ
> និយាយអំពីមូលហេតុនៅក្នុងប្រយោគខាងមុខ ហើយប្រាប់អំពីលទ្ធផលនៅប្រយោគខាងក្រោយ។
> · 지금 바빠서 그러는데 이것 좀 도와주세요.
> ដោយសារតែឥឡូវនេះរវល់ណាស់ ហេតុនេះហើយសូមជួយខ្ញុំបន្តិច។



តើអ្នកបានស្ដាប់និងថាតាមហើយមែនដែររឺទេ? អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 수피카 씨는 왜 흐엉을 만나고 싶어해요? ហេតុអ្វីបានជាស៊ូភីខាចង់ជួបជាមួយនឹងហៀអង?
2. 흐엉 씨는 한국어를 어떻게 공부해요? តើហៀអងរៀនភាសាកូរ៉េដោយរបៀបណា?

정답 1. 한국어를 배우고 싶어서요. 2. 한국 영화를 보면서 공부해요.

## 어휘 1 ពាក្យថ្មី ១ | 공부 ការរៀនសូត្រ



តើអ្នករៀនភាសាកូរ៉េតាមរបៀបណា? យើងនឹងរៀនពាក្យថ្មីៗដែលនិយាយអំពីការរៀនសូត្រ។



공부하다
ការរៀនសូត្រ



사전을 찾다
ស្វែងរកតាមវចនានុក្រម



예습하다
មើលមេរៀនទុកជាមុន



복습하다
រំលឹកមេរៀន



학원에 다니다
រៀននៅសាលា



인터넷 강의를 듣다
រៀនតាមអ៊ីនធឺណេត



CD를 듣다
ស្ដាប់ CD



따라하다
ថាតាម



쉽다
ងាយស្រួល



어렵다
លំបាក



សូមកុំមើលពាក្យនៅខាងលើ ហើយសាកល្បងដោះស្រាយសំណួរ។

1. 그림에 맞는 표현을 〈보기〉에서 골라 문장을 완성하세요.
សូមជ្រើសរើសកន្សោមពាក្យពី<ឧទាហរណ៍>យកមកបំពេញប្រយោគឲ្យបានត្រឹមត្រូវទៅនឹងរូបភាព។

1)  흐엉 씨는 매일 ____________.

2)  투안 씨는 ________________.

3)  리한 씨는 ________________.

4)  흐엉 씨는 매일 ____________.

**보기** 복습하다 예습하다 학원에 다니다 인터넷 강의를 듣다

**정답** 1) 예습해요 2) 학원에 다녀요 3) 인터넷 강의를 들어요 4) 복습해요

## 문법 1 វេយ្យាករណ៍ ១ | -(으)면서

G24-1

យើងប្រើប្រាស់ '(으)면서' ភ្ជាប់ជាមួយកិរិយាស័ព្ទ។ ដើម្បីនិយាយអំពីសកម្មភាព២ ធ្វើស្របគ្នាក្នុងពេលតែមួយ។ ដូចនេះហើយ ឃ្លានៅខាងមុខ និងឃ្លានៅខាងក្រោយ '(으)면서' អាចផ្លាស់ប្តូរគ្នាបាន និងមានអត្ថន័យដូចគ្នា។ ម្យ៉ាងវិញទៀត ឃ្លាទាំង២នេះ ត្រូវតែមានប្រធានតែមួយគត់។

| 자음(ព្យញ្ជនៈ) → -**으면서** | 모음(ស្រៈ), 자음 'ㄹ'(ព្យញ្ជនៈ 'ㄹ') → -**면서** |
|---|---|
| 먹다 → 먹**으면서** | 보다 → 보**면서**<br>울다 → 울**면서** |

- 영화를 **보면서** 빵을 먹어요. មើលភាពយន្តបណ្តើរ ហូបនំប៉័ងបណ្តើរ។
- 한국 노래를 **들으면서** 한국어를 공부해요. ស្តាប់បទចម្រៀងកូរ៉េបណ្តើរ រៀនភាសាកូរ៉េបណ្តើរ។
- 지훈 씨는 **학생이면서** 회사원이에요. ជីហ៊ូនគឺជាសិស្សផង ហើយក៏ជាបុគ្គលិកក្រុមហ៊ុនផង។
- 가: 투안 씨, 어제 저녁에 뭐 했어요? ធូអាន់, តើល្ងាចមិញបានធ្វើអ្វី?

  나: 친구하고 밥을 **먹으면서** 이야기했어요. ខ្ញុំបានជួបមិត្តភក្តិហូបបាយបណ្តើរ និយាយគ្នាលេងបណ្តើរ។

## 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

✔ រវាង '-(으)면서' និង '-고'

យើងប្រើប្រាស់ '-(으)면서' និង '-고' គឺដើម្បីនិយាយអំពីសកម្មភាព២ផ្សេងគ្នាដែលកើតឡើងស្របពេលតែ១ដូចគ្នា។ ខុសគ្នាត្រង់ថា ពេលដែលមានសកម្មភាព២ផ្សេងគ្នា កើតឡើងស្របគ្នាក្នុងពេលតែ១ យើងប្រើប្រាស់ '-(으)면서' ។ ចំណែកឯ '-고' វិញ សកម្មភាពទី១ បានកើតឡើងមុន, ស្របពេលដែលសកម្មភាពទី១មិនទាន់បានបញ្ចប់នៅឡើយ សកម្មភាពទី២ក៏ចូលមកដល់ បន្ទាប់មកក៏ធ្វើសកម្មភាព ទាំង២នេះស្របគ្នាតែម្តង។

- 손을 **잡으면서** 말씀하셨어요. គាត់បានចាប់ដៃខ្ញុំបណ្តើរ ហើយមានប្រសាសន៍បណ្តើរ។
- 손을 **잡고** 말씀하셨어요. គាត់បានចាប់ដៃខ្ញុំ រួចហើយមានប្រសាសន៍ឡើង។



តើអ្នកយល់អំពីការប្រើប្រាស់ '-(으)면서' ហើយមែនដែររឺទេ? អញ្ចឹងសូមមើលរូបភាព បន្ទាប់មកចូរបញ្ចប់ការសន្ទនាខាងក្រោមនេះ។

2. 그림을 보고 '-(으)면서'를 사용해서 대화를 완성하세요.

សូមមើលរូបភាព រួចហើយចូរប្រើប្រាស់ '-(으)면서' មកបញ្ចប់ការសន្ទនា។

1) 

사전을 찾다 | 공부하다

가: 모니카 씨는 어떻게 공부해요? តើម៉ូនីខារៀនដោយរបៀបណា?

나: 저는 모르는 단어는 ________________.

2) 

CD를 듣다 | 따라하다

가: 바루 씨는 참 발음이 좋네요. 어떻게 연습해요?

ការបញ្ចេញសម្លេងរបស់បារ៊ូពិតជាល្អខ្លាំងណាស់។ តើហ្វឹកហាត់ដោយរបៀបណា?

나: 저는 매일 ________________.

정답 1) 사전을 찾으면서 공부해요 2) CD를 들으면서 따라해요

## 대화 2 ការសន្ទនា ២

Track 77



រីហាន់កំពុងតែសួរធូអាន់អំពីការចុះឈ្មោះចូលរៀន។ តើចុះឈ្មោះចូលរៀនបានដោយរបៀបណា? ដំបូង សូមស្ដាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន។

**리한** 투안 씨, 어디 갔다 와요?
តើធូអាន់ទើបតែមកពីណា?

**투안** 자동차 정비 교육을 받고 왔어요.
나중에 고향에 돌아가서 일을 구할 때
도움이 될 것 같아서요.
ខ្ញុំទើបតែមកពីទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈជួសជុលរថយន្ត។ នៅពេលដែលត្រឡប់ទៅស្រុកកំណើតវិញ ប្រហែលជាវាអាចជួយឲ្យខ្ញុំរកការងារធ្វើបាន។

**리한** 저도 그 수업을 듣고 싶은데
그 수업은 어때요?
ខ្ញុំក៏ចង់រៀនដែរ, តើវគ្គបណ្ដុះបណ្ដាលនេះយ៉ាងម៉េចដែរ?

**투안** 지금 하는 일과 비슷해서
이해하기 쉬워요.
វាស្រដៀងនឹងការងារដែលធ្វើសព្វថ្ងៃនេះ អញ្ចឹងហើយងាយស្រួលយល់ណាស់។

**리한** 아, 그래요? 어떻게 신청해요?
អញ្ចឹងមែនរឺ? តើចុះឈ្មោះចូលរៀនបានដោយរបៀបណា?

**투안** 홈페이지에서 신청하면 돼요.
ចុះឈ្មោះចូលរៀនបានតាមរយៈគេហទំព័រ។

> **-(으)ㄹ 것 같다 ប្រហែលជា**
> ប្រើប្រាស់នៅពេលដែលនិយាយប៉ាន់ស្មាន (ទស្សទាយ) រឺក៏និយាយដោយស្ទាក់ស្ទើរអំពីអ្វីមួយ។
> - 비가 올 것 같아요. 우산을 가져가세요.
>   មេឃប្រហែលជាភ្លៀងហើយ។ សូមកាន់ឆ័ត្រទៅជាមួយផង។
> - 너무 바빠서 여행을 못 갈 것 같아요.
>   ខ្ញុំរវល់ខ្លាំងណាស់ ប្រហែលជាមិនអាចទៅដើរលេងបាននោះទេ។

> **-(으)면 되다**
> **បើ... ... បាន(លទ្ធផលសម្រេច)**
> បង្ហាញអំពីលក្ខខណ្ឌណាមួយដែលត្រូវអនុវត្តតាម លុះរួចរាល់អស់ហើយការងាររឺក៏បញ្ហានោះនឹងត្រូវបញ្ចប់រឺក៏គ្រប់គ្រាន់ឥតខ្ចោះចន្លោះ។
> - 오전 9시까지 오시면 돼요.
>   សូមមកដល់ទីនេះត្រឹមម៉ោង៩:០០ព្រឹក។
> - 여기에서 길을 건너면 됩니다.
>   ឆ្លងកាត់ផ្លូវមួយនេះគឺទៅដល់ហើយ។



សូមសាកល្បងដើរតួជាធូអាន់និងរីហាន់ ហើយចូរថាតាមការសន្ទនា។ តើអ្នកបានស្ដាប់និងថាតាមរួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 투안 씨는 무슨 교육을 받아요? តើធូអាន់កំពុងតែទទួលការអប់រំអ្វី?
2. 그 수업은 어떻게 신청해요? តើចុះឈ្មោះចូលរៀនវគ្គបណ្ដុះបណ្ដាលនោះតាមរបៀបណា?

**정답** 1. 자동차 정비 교육을 받아요. 2. 홈페이지에서 신청해요.

## 어휘 2 ពាក្យថ្មី ២ | 교육 ការអប់រំ



យើងនឹងស្វែងយល់អំពីពាក្យថ្មីខ្លះៗទៀតដែលទាក់ទងនឹងការអប់រំទាំងអស់គ្នា។



교육
ការអប់រំ/ការបណ្តុះបណ្តាល



과정
វគ្គសិក្សា



수업
ថ្នាក់រៀន



과목
មុខវិជ្ជា



일정
កាលវិភាគ



기관
ស្ថាប័ន



교실
បន្ទប់រៀន



자격증
វិញ្ញាបនបត្រ



개강
បើកបវេសនកាល/បើកវគ្គសិក្សា



종강
បញ្ចប់បវេសនកាល/បិទវគ្គសិក្សា



សូមរំលឹកពីពាក្យដែលបានរៀននៅខាងលើម្តងទៀត បន្ទាប់មកចូរសាកល្បងដោះស្រាយសំណួរខាងក្រោម។

1. 그림에 맞는 단어를 〈보기〉에서 골라 대화를 완성하세요.
សូមជ្រើសរើសយកពាក្យពី<ឧទាហរណ៍>មកបញ្ចប់ការសន្ទនាឲ្យបានត្រឹមត្រូវទៅនឹងរូបភាព។

1) 
가: 어떻게 오셨어요? តើអ្នកមកទីនេះមានការអ្វី?
나: 한국어 __________을 듣고 싶어요.

2) 
가: 언제 끝나요? តើនឹងបញ្ចប់នៅថ្ងៃណា?
나: __________은 4월 30일 이에요.

3) 
가: 어떤 __________이 있어요?
나: 한국, 컴퓨터, 태권도 반이 있어요.
មានថ្នាក់រៀនភាសាកូរ៉េ, ថ្នាក់កុំព្យូទ័រនិងថ្នាក់តែក្វាន់ដូ។

4) 
가: __________은 어디에 있어요?
나: 3층에 있어요. នៅជាន់ទី៣។

5) 
가: 언제 __________해요?
나: 다음 주 월요일에 시작해요. នឹងចាប់ផ្តើមនៅថ្ងៃច័ន្ទសប្តាហ៍ក្រោយ។

**보기** 종강 교실 개강 수업 과정

정답 1) 수업 2) 종강 3) 과정 4) 교실 5) 개강

## 문법 2 វេយ្យាករណ៍ ២ | -기 쉽다/어렵다

G24-2

យើងប្រើប្រាស់ '-기 쉽다/어렵다' ភ្ជាប់ជាមួយកិរិយាស័ព្ទ ដើម្បីបង្ហាញអំពីភាពងាយស្រួល រឺក៏ភាពលំបាកនៅពេលដែលធ្វើសកម្មភាពអ្វីមួយ។ យើងអាចផ្លាស់ប្តូរទម្រង់ 'V-기' ទៅជាទម្រង់ 'V-는 것이' បាន។

- 이 한국어 책은 **배우기 쉽고** 재미있어요.
  សៀវភៅភាសាកូរ៉េមួយនេះ មានភាពងាយស្រួលក្នុងការរៀន ហើយថែមទាំងគួរឲ្យចាប់អារម្មណ៍ទៀតផង។
- 낮에는 일하고 밤에는 대학원에 **다니기**가 **쉽지** 않아요.
  ពេលថ្ងៃខ្ញុំទៅធ្វើការ លុះដល់ពេលយប់ខ្ញុំទៅរៀនថ្នាក់ឧត្តមសិក្សាទៀត វាពិតជាមិនងាយស្រួលនោះទេ។

'V-기' មិនត្រឹមតែប្រើបានជាមួយ '쉽다/어렵다' ប៉ុណ្ណោះនោះទេ យើងអាចប្រើបានជាមួយគុណនាមជាច្រើនទៀតដូចជា៖ '좋다(ល្អ), 싫다(ស្អប់), 편하다(ស្រួល), 불편하다(អត់ស្រួល)' ។ល។

- 이곳은 가게가 많아서 **쇼핑하기** 아주 **좋아요**.
  ដោយសារនៅទីនេះមានហាងទំនិញជាច្រើន វាពិតជាមានភាពងាយស្រួលក្នុងការទិញឥវ៉ាន់ណាស់។
- 이 옷은 단추가 많아서 **입기 불편해요**. អាវនេះមានឡេវច្រើនណាស់ ពិតជាមិនងាយស្រួលក្នុងការពាក់នោះទេ។

### 크메르어와 한국어의 공통점과 차이점 ចំណុចដូចគ្នានិងខុសគ្នារវាងភាសាខ្មែរនិងភាសាកូរ៉េ

នៅក្នុងភាសាខ្មែរ ដូចជាឃ្លាថា '이 문은 열기 쉽다.'(ទ្វារនេះ ស្រួលបើក។) គឺយើងអាចយកពាក្យមកពណ៌នាអំពីភាពលំបាក ឬងាយស្រួលក្នុងការធ្វើរឿងអ្វីមួយបាន។ ក៏ប៉ុន្តែនៅក្នុងភាសាកូរ៉េវិញ ជាដំបូងគឺត្រូវធ្វើការភ្ជាប់ '-기' ពីក្រោយកិរិយាស័ព្ទដើម្បីប្តូរវាទៅនាមជាមុនសិន បន្ទាប់មកទើបបន្ថែម '쉽다'(ស្រួល) ឬក៏ '어렵다'(ពិបាក) ពីខាងក្រោយ។

- 이 문은 **열기 쉽다**. ទ្វារនេះ ស្រួលបើក។
- 이 책의 내용은 **이해하기 어렵다**. ខ្លឹមសារសៀវភៅនេះ ពិបាកយល់។



តើអ្នកយល់ពីការប្រើប្រាស់ '-기 쉽다 /어렵다' ហើយមែនដែររឺទេ? អញ្ចឹងសូមជ្រើសរើសយកល្បះដែលត្រឹមត្រូវនឹងការសន្ទនាខាងក្រោមនេះ។

2. 대화를 읽고 맞는 대답을 고르세요. សូមអានការសន្ទនា រួចជ្រើសរើសយកចម្លើយ។

1)
가: 저하고 같이 저녁에 컴퓨터 학원에 다닐래요?
　　តើអ្នកទៅរៀនសាលាកុំព្យូទ័រពេលល្ងាចជាមួយខ្ញុំដែររឺទេ?
나: 저녁에는 일을 해야 돼서 ______________________.

① 학원에 다니기 쉬워요　　② 학원에 다니기 어려워요

2)
가: 한국어 공부를 하고 싶은데 어떤 책이 좋아요?
　　ខ្ញុំចង់រៀនភាសាកូរ៉េ តើសៀវភៅមួយណាល្អ?
나: 이 책을 보세요. ______________________.

① 이 책은 재미있어서 공부하기 쉬워요　　② 이 책은 재미있어서 공부하기 어려워요

정답 1) ② 2) ①

## 활동 សកម្មភាព

주말 한국어 교육에 관한 안내문입니다. 잘 읽고 질문에 답하세요.
សេចក្តីជូនដំណឹងពីការអប់រំភាសាកូរ៉េនាចុងសប្តាហ៍។ សូមអានដោយយកចិត្តទុកដាក់និងឆ្លើយសំណួរខាងក្រោម។

### 외국인 근로자를 위한 주말 한국어 교육

- 과 정: 한국어 초급, 중급, 고급
- 개 강: 9월 2일
- 종 강: 10월 31일
- 시 간: 매주 토요일 오후 2시~4시
- 교 실: 외국인센터 503호
- 수업료: 무료
- 문 의: 031) 9999-1249 (월~토 오전 9시~오후 6시)

### ការបង្រៀនភាសាកូរ៉េនាចុងសប្តាហ៍សម្រាប់ពលករបរទេស

- វគ្គសិក្សា៖ ភាសាកូរ៉េកម្រិតដំបូង, កម្រិតមធ្យម, កម្រិតខ្ពស់
- បើកវគ្គសិក្សា៖ ថ្ងៃទី០២ ខែកញ្ញា
- បិទវគ្គសិក្សា៖ ថ្ងៃទី៣១ ខែតុលា
- ម៉ោងសិក្សា៖ រៀងរាល់ថ្ងៃសៅរ៍ ល្ងាចម៉ោង២:០០~ម៉ោង៤:០០
- បន្ទប់រៀន៖ មជ្ឈមណ្ឌលជនជាតិបរទេស បន្ទប់លេខ៥០៣
- ថ្លៃសិក្សា៖ មិនគិតថ្លៃ
- ទំនាក់ទំនង៖ ០៣១)៩៩៩៩-១២៤៩ (ថ្ងៃច័ន្ទ~ថ្ងៃសុក្រ, ម៉ោង៩:០០ព្រឹក~ម៉ោង៦:០០ល្ងាច)

1. 어떤 과정에 대한 안내문입니까? តើជាសេចក្តីជូនដំណឹងអំពីអ្វី?
   ① 요리 수업　　② 한국어 수업
   ③ 태권도 수업　　④ 컴퓨터 수업

2. 읽은 내용과 같으면 ○, 다르면 X에 표시하세요.
   ប្រសិនបើដូចទៅនឹងខ្លឹមសារដែលអ្នកបានអានសូមជ្រើសរើស○, បើខុសវិញសូមជ្រើសរើសX។
   1) 돈을 내지 않아도 됩니다.　○　X
   2) 두 달 동안 교육을 받습니다.　○　X
   3) 인터넷으로 강의를 듣습니다.　○　X
   4) 주말 오전에 수업이 있습니다.　○　X

정답 1. ② 2. 1) O 2) O 3) X 4) X

**정보** ព័ត៌មាន

## 외국인 근로자 교육 프로그램

កម្មវិធីអប់រំ(បណ្តុះបណ្តាល)សម្រាប់ពលករបរទេស

한국산업인력공단에서는 외국인근로자가 한국에 있는 동안 한국어 및 필요 기능을 습득하여 체류 기간이 끝나면 본국에 안정적으로 재정착할 수 있도록 지원하는 교육프로그램을 제공하고 있습니다. 각 프로그램은 현지 기업과 근로자의 수요 조사를 통해 현지 재취업 혹은 창업에 필요한 과정으로 구성되어 있습니다. 제조업, 건설업, 농축산업, 어업 등 현장에서 실용적이고 안전 관리와 관련된 기초 직무 교육뿐만 아니라 컴퓨터 수리, 자동차 정비, 용접 교육 등 전문기술능력을 향상시키는 프로그램도 포함되어 있는데, 이러한 교육은 한국산업인력공단 홈페이지에서 교육프로그램을 확인한 후 신청하면 체류 기간 동안 누구나 교육을 받을 수 있습니다.

ស្ថាប័នអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណៈរដ្ឋកូរ៉េបានផ្តល់កម្មវិធីបណ្តុះបណ្តាលជាច្រើនដល់ពលករបរទេសដែលមានដូចជា៖ ការបង្រៀនភាសាកូរ៉េ ឬក៏មុខជំនាញផ្សេងៗដែលចាំបាច់នៅពេលផុតអណ្តិតទៅ ដែលអាចធ្វើឲ្យពលករមានស្ថិរភាពផ្នែកហិរញ្ញវត្ថុពេលត្រឡប់ទៅស្រុកកំណើតវិញ។ កម្មវិធីបណ្តុះបណ្តាលទាំងអស់នោះ បង្កើតឡើងតាមរយៈការស្ទង់មតិជាក់ស្តែងពីក្រុមហ៊ុនតាំងនៅមូលដ្ឋាន (ស្រុកកំណើត) អំពីតម្រូវការពលកម្មដែលអាចអោយពលករមានឱកាសរកការងារ ឬក៏អាចបើកមុខជំនួញពេលត្រឡប់ទៅស្រុកកំណើតវិញ។ ការបណ្តុះបណ្តាលមានជាអាទិ៍៖ ការងារមូលដ្ឋានដែលទាក់ទងនឹងការអនុវត្តជាក់ស្តែងនិងរក្សាសុវត្ថិភាពនៅក្នុងវិស័យឧស្សាហកម្ម, សំណង់, កសិកម្ម, ជលផល។ល។ មិនត្រឹមតែប៉ុណ្ណោះ ការបណ្តុះបណ្តាលនេះក៏មានបញ្ចូលកម្មវិធីនានាដើម្បីពង្រឹងជំនាញវិជ្ជាជីវៈជាច្រើនទៀតដូចជា៖ ជួសជុលកុំព្យូទ័រ, ជួសជុលរថយន្ត, ផ្សារដែកជាដើម។ អ្នកអាចស្វែងរកកម្មវិធីទាំងអស់នេះបានតាមរយៈគេហទំព័រស្ថាប័នអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណៈរដ្ឋកូរ៉េ។ នៅក្នុងកំឡុងពេលស្នាក់នៅ នរណាក៏អាចទទួលបានវគ្គបណ្តុះបណ្តាលទាំងអស់នេះបានដែរ ដោយគ្រាន់តែចូលទៅពិនិត្យកម្មវិធីបណ្តុះបណ្តាល ហើយចុះឈ្មោះរួចជាការស្រេច។

### 교육 프로그램 신청 ការចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាល

1) 한국산업인력공단 홈페이지(http://eps.hrdkorea.or.kr)에서 교육 프로그램 리스트를 검색하세요. (나에게 맞는 교육 프로그램 찾기)
   ចូលទៅកាន់គេហទំព័រស្ថាប័នអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណៈរដ្ឋកូរ៉េតាមរយៈ៖ http://eps.hrdkorea.or.kr ហើយស្វែងរកតារាងនៃវគ្គបណ្តុះបណ្តាល។ (ស្វែងរកវគ្គបណ្តុះបណ្តាលដែលសមស្របនឹងខ្ញុំ)

2) 각 과정별 교육 조건을 확인하세요.
   (신청 자격, 신청 시기, 교육 시기, 교육 기관, 수료 조건 등)
   ជ្រើសរើសយកការយល់ព្រមអំពីលក្ខខណ្ឌនីមួយៗនៅក្នុងដំណើរការនៃវគ្គបណ្តុះបណ្តាល។ (លក្ខខណ្ឌដែលអាចចុះឈ្មោះចូលរៀនបាន, កាលបរិច្ឆេទចុះឈ្មោះ, កាលបរិច្ឆេទចូលរៀន, ទីកន្លែងសិក្សា, លក្ខខណ្ឌដើម្បីបញ្ចប់ការសិក្សា។ល។)

3) 신청하기 버튼을 클릭하여 본인의 인적사항을 기재한 후 전송하세요.
   ចុចទៅលើពាក្យ "ចុះឈ្មោះ" បន្ទាប់មកបំពេញព័ត៌មានផ្ទាល់ខ្លួន រួចហើយចុចបញ្ជូន។

4) 사이트 방문 혹은 이메일을 통해 교육대상자로 선정되었는지 확인하세요.
   ពិនិត្យម្តងទៀតថាជាប់ឈ្មោះជាអ្នកចូលរៀនវគ្គបណ្តុះបណ្តាលហើយរឺក៏នៅ តាមរយៈអ៊ីមែល។

5) 시간과 장소를 확인하여 교육에 참여하세요.
   ចូរពិនិត្យមើលពេលវេលានិងទីកន្លែងនៃវគ្គបណ្តុះបណ្តាលឲ្យបានច្បាស់លាស់ រួចហើយអ្នកអាចចូលរួមវគ្គបណ្តុះបណ្តាលបានហើយ។



# EPS-TOPIK 듣기 វិញ្ញាសាស្ដាប់ EPS-TOPIK



ចាប់ពីសំណួរទី១ដល់ទី៣គឺជាការស្ដាប់សំណួរ បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវ។
សូមមើលចម្លើយដែលបានផ្ដល់ឲ្យដូចខាងក្រោមជាមុនសិនមុននឹងស្ដាប់សំណួរ។

[1~3] 질문을 듣고 알맞은 대답을 고르십시오.
សូមស្ដាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

Track 78

1. ① 열심히 공부했어요.
   ② 인터넷 강의를 들어요.
   ③ 한국어는 조금 어려워요.
   ④ 한국어 공부를 열심히 해야 돼요.

2. ① 수업은 저녁 7시에 시작돼요.
   ② 저는 매일 예습하고 복습해요.
   ③ 저녁에는 학원에 가기 어려워요.
   ④ 어제 저녁에 학원에서 만났어요.

3. ① 고급 과정은 없어요.
   ② 10월 31일에 끝나요.
   ③ 다음 주 월요일이에요.
   ④ 외국어교육센터 503호예요.



បន្ទាប់ទៅនេះចូរស្ដាប់ការសន្ទនា រួចជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។
មុននឹងស្ដាប់ការសន្ទនា សូមអានសំណួរដែលបានបង្ហាញខាងក្រោមនេះជាមុនសិន។

[4~5] 하나의 이야기를 듣고 두 개의 질문에 대답하십시오.
សូមស្ដាប់ការនិយាយតែមួយគត់ បន្ទាប់មកចូរឆ្លើយនឹងសំណួរទាំង២។

4. 남자는 왜 전화를 했습니까? ហេតុអ្វីបានជាបុរសម្នាក់នេះទូរស័ព្ទ?
   ① 한국어 책을 사고 싶어서 ② 한국어를 공부하고 싶어서
   ③ 한국 친구를 사귀고 싶어서 ④ 토요일에 한국어 시험이 있어서

5. 한국어 초급반 수업은 언제 있습니까? តើថ្នាក់ភាសាកូរ៉េកម្រិតដំបូងរៀននៅពេលណា?
   ① 토요일 10:00~12:00 ② 토요일 10:00~13:00
   ③ 토요일 11:00~13:00 ④ 토요일 11:00~14:00



## 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្ដាប់

1. 여: 투안 씨는 한국어 공부를 어떻게 해요? តើធូអាន់រៀនភាសាកូរ៉េតាមរបៀបណា?
2. 남: 모니카 씨, 저녁에 같이 학원에 다닐래요? តើម៉ូនីខាទៅរៀននៅសាលាភាសាកូរ៉េជាមួយគ្នាដែររឺទេ?
3. 남: 개강이 언제예요? តើគេបើកវគ្គសិក្សានៅពេលណា?

4–5. 여: 여보세요. 한국어교육센터입니다. ជម្រាបសួរ, ទីនេះគឺជាសាលាភាសាកូរ៉េ។

남: 저, 한국어능력시험 준비 과정이 있어요?
អត់ទោស, ខ្ញុំសុំសួរថាតើទីនោះមានថ្នាក់បង្រៀនត្រៀមក្នុងការប្រលងធ្វើតេស្តសមត្ថភាពភាសាកូរ៉េដែររឺទេ?

여: 네, 초급반하고 중급반이 있어요. ចាំ! មានថ្នាក់កម្រិតដំបូងនិងថ្នាក់កម្រិតមធ្យម។

남: 초급반 수업은 몇 시에 해요? តើថ្នាក់កម្រិតដំបូងរៀននៅម៉ោងប៉ុន្មានដែរ?

여: 토요일 오전 10시부터 오후 1시까지예요. នៅថ្ងៃសៅរ៍ ចាប់ពីម៉ោង១០:០០ព្រឹកដល់ម៉ោង១:០០រសៀល។

정답 1. ② 2. ③ 3. ③ 4. ② 5. ②

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-24

[1~2] 질문을 듣고 알맞은 대답을 고르십시오. សូមស្ដាប់សំណួរ បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

1. ① 두 시에 할 거예요. ② 아주 안전할 거예요.
   ③ 내일 하기로 했어요. ④ 센터에서 하기로 했어요.

2. ① 네, 강의를 신청하고 싶어요. ② 네, 인터넷으로 물건을 사요.
   ③ 네, 저녁마다 강의를 들어요. ④ 네, 매일 인터넷 검색을 해요.

## 확장 연습 듣기 대본 អត្ថបទស្ដាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 내일 안전 교육은 어디에서 해요? តើការអប់រំអំពីសុវត្ថិភាពធ្វើឡើងនៅឯណា?
2. 남: 흐엉 씨, 매일 인터넷으로 강의를 들어요? តើហៀងស្ដាប់ការបង្រៀនតាមរយៈអ៊ីនធឺណេតជារៀងរាល់ថ្ងៃរឺ?

정답 1. ④ 2. ③

## 발음 ការបញ្ចេញសម្លេង

P-11

### សូមស្ដាប់ដោយយកចិត្តទុកដាក់ រួចចូរថាតាម។

នៅក្នុងភាសាកូរ៉េ ការបញ្ចេញសម្លេងរបស់ជើងព្យញ្ជនៈគឺមានដែនកំណត់។ ក្នុងព្យញ្ជនៈទាំងអស់ មានជើងព្យញ្ជនៈ ត្រឹមតែ៧ប៉ុណ្ណោះ ដែលអាចបញ្ចេញសម្លេងរបស់ខ្លួនបាន។ ជើងព្យញ្ជនៈដែលមានជាអាទិ៍ដូចជា៖ ‘ㄷ[t], ㅌ[tʰ], ㅅ[s], ㅆ[s’], ㅈ[ʧ], ㅊ[ʧʰ]’ មិនអាចបញ្ចេញសម្លេងដើមរបស់ខ្លួនបានឡើយ។ ជើងព្យញ្ជនៈដែលបានលើកបង្ហាញខាងលើនេះគឺដូចជាជើង ‘은’ អញ្ចឹង ត្រូវបញ្ចេញសម្លេងជា [ㄷ] ទាំងអស់។

(1) 솥, 밭, 옷, 닫다, 돋보기, 있다
(2) 낫 : 낮 : 낯
(3) 빗 : 빚 : 빛
(4) 솥도 커요.
(5) 가게에는 옷도 있다.

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK



ចាប់ពីសំណួរទី១ដល់ទី៣គឺជាការជ្រើសរើសយកចម្លើយដែលត្រឹមត្រូវដើម្បីបំពេញល្បះ។ សូមរំលឹកអំពីកន្សោមពាក្យដែលអ្នកបានរៀនរួចមកហើយនោះបណ្តើរ បន្ទាប់មកធ្វើការដោះស្រាយសំណួរបណ្តើរ។

[1~3] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសយកកន្សោមពាក្យដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

1.
가: ___________이 언제예요? តើបិទវគ្គសិក្សានៅថ្ងៃណា?
나: 8월 30일에 끝나요. នឹងបញ្ចប់នៅថ្ងៃទី៣០ ខែសីហា។

① 수업 ② 일정 ③ 개강 ④ 종강

2.
가: 무슨 ___________을 제일 좋아해요? តើអ្នកចូលចិត្តរៀនមុខវិទ្យាមួយណា?
나: 역사를 제일 좋아해요. ខ្ញុំចូលចិត្តប្រវត្តិវិទ្យាខ្លាំងជាងគេ។

① 과목 ② 기관 ③ 교실 ④ 학원

3.
저는 매일 아침부터 저녁까지 회사에서 일을 합니다. 일이 끝나면 한국어를 배우러 학원에 갑니다. 일을 ___________ 학원에 다니는 것은 힘들지만 일을 할 때 도움이 많이 됩니다.
ខ្ញុំទៅធ្វើការចាប់តាំងពីព្រលឹមដល់ព្រលប់ ជារៀងរាល់ថ្ងៃ។ ក្រោយចេញពីធ្វើការ ខ្ញុំទៅមជ្ឈមណ្ឌលភាសារៀនភាសាកូរ៉េថែមទៀតផង។ ធ្វើការបណ្តើរ រៀនបណ្តើរលំបាកបន្តិចក៏ពិតមែន ប៉ុន្តែវាអាចជួយខ្ញុំច្រើននៅពេលធ្វើការងារ។

① 하러 ② 하면서 ③ 했는데 ④ 하기로



បន្ទាប់ទៅនេះ ជាសេចក្តីជូនដំណឹង។ តើវាជាកម្មវិធីអប់រំអ្វី? ហើយកម្មវិធីនេះធ្វើឡើងនៅពេលណា? សូមគិតបណ្តើរនិងឆ្លើយសំណួរបណ្តើរ។

[4~5] 다음 글을 읽고 물음에 답하십시오. សូមអានអត្ថបទខាងក្រោម រួចហើយចូរឆ្លើយនឹងសំណួរ។

〈무료 한국어 교실 (4개월 과정)〉
< ថ្នាក់ភាសាកូរ៉េរៀនដោយឥតគិតថ្លៃ (រៀនរយៈពេល៤ខែ) >

| 시간/요일 ម៉ោងសិក្សា/ថ្ងៃសិក្សា | 토요일 ថ្ងៃសៅរ៍ | 일요일 ថ្ងៃអាទិត្យ |
|---|---|---|
| 13:00~15:00 | 초급 ថ្នាក់កម្រិតដំបូង | 중급 ថ្នាក់កម្រិតមធ្យម |
| 15:00~17:00 | 초급 ថ្នាក់កម្រិតដំបូង | 고급 ថ្នាក់កម្រិតខ្ពស់ |

* 개강: 3월 1일 បើកវគ្គសិក្សា៖ ថ្ងៃទី០១ ខែមីនា
* 신청: 센터 직접 방문 (2월 15일까지) ការចុះឈ្មោះចូលរៀន៖ នៅមជ្ឈមណ្ឌលដោយផ្ទាល់ (ត្រឹមថ្ងៃទី១៥ ខែកុម្ភៈ)

4. 이 안내문의 내용과 다른 것을 고르십시오. សូមជ្រើសរើសយកចម្លើយដែលខុសពីសេចក្តីជូនដំណឹង។
① 수업료를 안 내도 됩니다. ② 3월에 신청할 수 있습니다.
③ 센터에 가서 신청해야 합니다. ④ 4개월 동안 한국어를 배웁니다.

5. 한국어 중급 수업은 언제 있습니까? តើភាសាកូរ៉េថ្នាក់កម្រិតមធ្យមរៀននៅពេលណា?
① 토요일 오후 1시~3시 ② 토요일 오후 3시~5시
③ 일요일 오후 1시~3시 ④ 일요일 오후 3시~5시

정답 1. ④ 2. ① 3. ② 4. ② 5. ③



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~2] 빈칸에 들어갈 가장 알맞은 것을 고르십시오.
សូមជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

1.

> 저는 드라마를 이용해서 한국어 공부를 합니다. 한국 드라마를 ________ 한국어를 공부하면 더 재미있게 공부할 수 있어서 좋습니다.
> ខ្ញុំប្រើប្រាស់ការមើលរឿងភាគកូរ៉េសម្រាប់ជាការរៀនភាសាកូរ៉េ។ ប្រសិនបើមើលរឿងភាគកូរ៉េបណ្ដើរ ហើយរៀនបណ្ដើរនោះ វាកាន់តែធ្វើឲ្យសប្បាយ ហើយថែមទាំងជក់ចិត្តក្នុងការរៀនទៀតផង។

① 보면서　② 보든지　③ 보거든　④ 보니까

2.

> 지난달부터 한국어를 배우기 시작했습니다. 수업이 끝나면 CD를 ________ 복습을 합니다.
> ខ្ញុំចាប់ផ្ដើមរៀនភាសាកូរ៉េតាំងពីខែមុនមកម្ល៉េះ។ បន្ទាប់ពីរៀនចប់នៅសាលាហើយ ខ្ញុំស្ដាប់CDបណ្ដើរ រំលឹកមេរៀនឡើងវិញបណ្ដើរ។

① 찾지만　② 듣지만　③ 찾으면서　④ 들으면서

[3~4] 다음 글을 읽고 무엇에 대한 글인지 고르십시오.
សូមអានកថាខណ្ឌខាងក្រោម បន្ទាប់មកចូរជ្រើសរើសថាតើកថាខណ្ឌនីមួយៗនិយាយអំពីអ្វី?

3.

> 저는 토요일마다 외국인력지원센터에서 한국어를 공부합니다. 집에 와서 수업 시간에 배운 단어와 문법을 복습하고 모르는 것이 있으면 한국인 동료에게 물어봅니다. 이렇게 하다 보니 한국어 실력이 빨리 좋아지는 것 같습니다.
> ជារៀងរាល់ថ្ងៃសៅរ៍ ខ្ញុំតែងតែទៅរៀនភាសាកូរ៉េនៅឯមជ្ឈមណ្ឌលគាំទ្រជនបរទេស។ ពេលទៅដល់ផ្ទះខ្ញុំយកពាក្យគន្លឹះ ឬក៏វេយ្យាករណ៍ដែលបានរៀននៅក្នុងថ្នាក់មករំលឹកឡើងវិញ។ ប្រសិនបើមានកន្លែងណាដែលមិនចេះ ខ្ញុំយកទៅសួរមិត្តរួមការងារដែលជាជនជាតិកូរ៉េឲ្យជួយពន្យល់។ ដោយធ្វើបែបនេះហើយ ទើបសមត្ថភាពនៃភាសាកូរ៉េរបស់ខ្ញុំហាក់ដូចជាល្អប្រសើរលឿនណាស់។

① 한국어 센터 소개　② 한국어 공부 방법
③ 한국어 수업 시간　④ 한국어 과목 안내

4.

> 이번 주 금요일 다섯 시에 강당에서 안전 교육이 있습니다. 지난 상반기 교육을 받지 않은 분들은 반드시 참석해 주시기 바랍니다. 교육 시간은 약 두 시간 정도입니다.
> នៅថ្ងៃសុក្រសប្ដាហ៍នេះវេលាម៉ោង៦:០០ឯសាលប្រជុំមានការអប់រំមួយស្ដីអំពីសុវត្ថិភាព។ ចំពោះអ្នកដែលមិនបានចូលរួមការអប់រំមួយនេះកាលពីដើមឆមាស ត្រូវតែចូលរួមកម្មវិធីម្ដងនេះកុំឲ្យខកខាន។ ពេលវេលាក្នុងការអប់រំកម្មវិធីនេះប្រហែលមានរយៈពេល២ម៉ោង។

① 교육 과정　② 교육 안내
③ 교육 과목　④ 교육 신청

정답 1. ① 2. ④ 3. ② 4. ②